អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន
# របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

បន្ទាប់ពីទទួលបានការតែងតាំងនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបន្តការស៊ើបអង្កេតលើសំណុំរឿង ០០៣ និង ០០៤ ដោយរំពឹងថា អ្វីដែលត្រូវបានលើកឡើងនៅក្នុងសារព័ត៌មានថាជាសម្តីរបស់នាយករដ្ឋមន្ត្រីកម្ពុជាដែលជម្រាបជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ថា “នឹងមិនអនុញ្ញាតឲ្យមានសំណុំរឿងទាំងពីរនេះ” មិនបានឆ្លុះបញ្ចាំងពីគោលនយោបាយទូទៅរបស់រាជរដ្ឋាភិបាលកម្ពុជាទេ។

ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ រដ្ឋមន្ត្រីក្រសួងព័ត៌មាននៃប្រទេសកម្ពុជាបានមានប្រសាសន៍ថា “ប្រសិនបើពួកគេចង់ដំណើរការរឿងក្តី ០០៣ និង ០០៤ ពួកគេគួរតែរៀបចំឥវ៉ាន់ហើយចាកចេញ”។

បើទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តើមនីតិវិធីស្តីពីការប្រមាថតុលាការ ប្រឆាំងនឹងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ហើយលោករំពឹងថា ការធ្វើដូច្នេះនឹងជាការព្រមានដល់មន្ត្រីដទៃទៀតនៃរដ្ឋាភិបាល កាលពីសប្តាហ៍កន្លងទៅនេះរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាត្រូវបានលើកឡើងនៅក្នុងសារព័ត៌មាន ថាបានថ្លែងថា “ការចាប់ខ្លួនអតីតមេដឹកនាំខ្មែរក្រហមបន្ថែមទៀតគឺជារឿងរបស់កម្ពុជា។ រឿងនេះត្រូវតែសម្រេចដោយកម្ពុជា។” (កាសែតខេមបូឌាដេលី ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១១)

បើទោះបីជាសហចៅក្រហមស៊ើបអង្កេតអន្តរជាតិមិនដាក់ខ្លួនគាត់ឲ្យស្ថិតនៅក្រោមឥទ្ធិពលនៃការលើកឡើងខាងលើនេះក៏ដោយ ក៏នៅតែមានភាពមន្ទិលសង្ស័យទៅលើលទ្ធភាពរបស់លោកក្នុងការទ្រាំទ្រនឹងសម្ពាធពីមន្ត្រីរាជរដ្ឋាភិបាល និងលទ្ធភាពក្នុងការបំពេញការងាររបស់លោកដោយឯករាជ្យ ហើយក៏បង្កឲ្យមានមន្ទិលសង្ស័យចំពោះសុចរិតភាពនៃដំណើរការទាំងមូលរបស់តុលាការក្នុងសំណុំរឿង ០០៣ និង ០០៤ ដែរ។

ដោយសារតែការលើកឡើងម្តងហើយម្តងទៀតទាំងនេះ ដែលនឹងធ្វើឲ្យគេយល់ឃើញថាជាការប៉ុនប៉ងជ្រៀតជ្រែករបស់មន្ត្រីរដ្ឋាភិបាលនៅក្នុងដំណើរការសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ ២០១១ បានបញ្ជូនពាក្យសុំលាលែងពីតួនាទីរបស់លោកទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥ (០)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh